Australian Government
Services Australia

KHMER

# គម្រោង Paid Parental Leave

# ការនិយាយទៅកាន់និយោជិតរបស់អ្នកអំពី Paid Parental Leave

គម្រោង Paid Parental Leave អនុញ្ញាតឱ្យអ្នកក្នុងនាមជានិយោជក ផ្ដល់ពេលវេលាឈប់សម្រាកពីការងារដល់និយោជិតរបស់អ្នកតាមរយៈ Parental Leave Pay (ប្រាក់ឧបត្ថម្ភការឈប់សម្រាកសម្រាប់ឪពុកម្ដាយនៅពេលទារក កើតមក និងការសុំកូន)។

Parental Leave Pay គឺជាប្រាក់ឧបត្ថម្ភផ្ដល់ជូនពួកគេដើម្បីឈប់សម្រាកពីការងារសម្រាប់ថែរក្សាកូនទើបនឹងកើត ឬកូនដែលបានសុំយកមកចិញ្ចឹមក្នុងពេលថ្មីៗនេះ ឬក្នុងករណីដែលនិយោជិតជួបប្រទះនូវការកើតកូនដែលស្លាប់ក្នុងផ្ទៃ ឬការស្លាប់របស់ទារក។

និយោជិតរបស់អ្នកចាំបាច់ត្រូវដាក់ពាក្យស្នើសុំ Parental Leave Pay មកយើង និងពិភាក្សាជាមួយអ្នកអំពីការរៀបចំការឈប់សម្រាក។

## ការពិភាក្សាអំពីការឈប់សម្រាកសម្រាប់ឪពុកម្តាយនៅពេលទារកកើតមក និងការសុំកូន

ប្រសិនបើនិយោជិតរបស់អ្នកនឹងមានកូន ឬទទួលយកកូនមកចិញ្ចឹម សូមពិភាក្សាជាមួយពួកគេឱ្យបានឆាប់អំពីផែនការរបស់ពួកគេ។

ប្រធានបទមួយចំនួនដែលត្រូវពិភាក្សា មានដូចជា៖

- ប្រភេទនៃការឈប់សម្រាកដែលពួកគេអាចយកបាន
- ថាតើពួកគេអាចយកការឈប់សម្រាកផ្សេងទៀតក្នុងពេលតែមួយជាមួយ Parental Leave Pay បានដែរឬទេ (ឧទាហរណ៍ ការឈប់សម្រាកដែលមានបៀវត្សរ៍ ឬគ្មានបៀវត្សរ៍)
- ពេលណាដែលពួកគេចង់ចាប់ផ្ដើមឈប់សម្រាក និងពេលណាដែលពួកគេរំពឹងថានឹងត្រឡប់មកធ្វើការវិញ
- របៀបដែលពួកគេចង់ត្រឡប់មកធ្វើការវិញ (ឧទាហរណ៍ ការត្រឡប់មកធ្វើការវិញក្រៅម៉ោង)
- ព័ត៌មានដែលពួកគេត្រូវផ្ដល់ឱ្យយើងអំពីអាជីវកម្មរបស់អ្នក នៅពេលពួកគេដាក់ពាក្យស្នើសុំ Parental Leave Pay។

# របៀបដែល Paid Parental Leave scheme ប៉ះពាល់ដល់ការឈប់សម្រាកផ្សេងទៀត

- គម្រោងនេះមិនផ្តល់សិទ្ធិដល់និយោជិតរបស់អ្នក ក្នុងការទទួលបានការឈប់សម្រាកនេះដោយស្វ័យប្រវត្តិទេ។ ពួកគេត្រូវតែបំពេញតាមលក្ខខណ្ឌនានាដើម្បីទទួលបាន Parental Leave Pay។
- Parental Leave Pay មិនផ្លាស់ប្តូរការឈប់សម្រាកផ្សេងទៀតដែលនិយោជិតរបស់អ្នកត្រូវបានអនុញ្ញាតនៅក្រោមកិច្ចព្រមព្រៀងសហគ្រាស ឬច្បាប់នោះទេ។
- អ្នកមិនអាចបដិសេធការឈប់សម្រាកសម្រាប់ម្តាយ ឬឪពុកម្តាយនៅពេលទារកកើតមក និងការសុំកូនដែលបានផ្តល់ប្រាក់ឧបត្ថម្ភដល់និយោជិតរបស់អ្នកបានទេ ប្រសិនបើវាជាផ្នែកមួយនៃកិច្ចព្រមព្រៀងសហគ្រាស ឬច្បាប់។ នេះមានសុពលភាពដរាបណាកិច្ចព្រមព្រៀង ឬច្បាប់នោះនៅមានសុពលភាព។

សម្រាប់ព័ត៌មានអំពីសិទ្ធិនៅកន្លែងធ្វើការ និងច្បាប់នានាជាភាសាអង់គ្លេស និងភាសាជាង 30 ផ្សេងទៀត សូមចូលទៅកាន់គេហទំព័រ **fairwork.gov.au** ឬទូរសព្ទទៅ Fair Work Ombudsman (អាជ្ញាធរដោះស្រាយពាក្យបណ្តឹង សមភាពការងារ) តាមលេខ **131 394**។

# សម្រាប់ព័ត៌មានបន្ថែម

- ចូលទៅកាន់ **servicesaustralia.gov.au/pplemployers**
- ចូលទៅកាន់ **servicesaustralia.gov.au/proda** ដើម្បីទទួលបានព័ត៌មានអំពីការចុះឈ្មោះអាជីវកម្មរបស់អ្នក
- ចូលទៅកាន់ **servicesaustralia.gov.au/yourlanguage** ជាកន្លែងដែលអ្នកអាចអាន ស្តាប់ ឬមើលព័ត៌មានជាភាសារបស់អ្នក។
- សូមទូរសព្ទមកយើងតាមលេខ **131 158** ឬ **131 202** ដើម្បីនិយាយជាមួយយើងជាភាសារបស់អ្នក។

# ការបដិសេធ

ព័ត៌មានដែលមាននៅក្នុងការបោះពុម្ពផ្សាយនេះ គឺមានគោលបំណងត្រឹមតែជាការណែនាំអំពីការទូទាត់ និងសេវាកម្មប៉ុណ្ណោះ។ វាជាទំនួលខុសត្រូវរបស់អ្នកក្នុងការសម្រេចចិត្តថាតើអ្នកចង់ដាក់ពាក្យសុំប្រាក់ឧបត្ថម្ភ និងធ្វើការដាក់ពាក្យឬអត់ ទាក់ទងនឹងកាលៈទេសៈជាក់លាក់របស់អ្នក។

Australian Government
Services Australia

ENGLISH

# The Paid Parental Leave scheme

# Talking to your employees about Paid Parental Leave

The Paid Parental Leave scheme allows you as an employer to give your employees time off work through Parental Leave Pay.

Parental Leave Pay is a payment for them to take time off work to care for a newborn or recently adopted child or where the employee has had a stillbirth or infant death.

Your employee needs to apply for Parental Leave Pay with us and talk to you about leave arrangements.

## Talking about parental leave

If your employee is having a baby or adopting a child, talk to them early about their plans.

Some topics to talk about are:

- what leave they can take
- whether they can take other leave at the same time as Parental Leave Pay (for example, paid or unpaid leave)
- when they want to start their leave and when they expect to return to work
- how they want to return to work (for example returning part time)
- information they need to give us about your business when they lodge a claim for Parental Leave Pay.

## How the Paid Parental Leave scheme affects other leave

- The scheme does not automatically give your employees access to this leave. They must meet the rules to get the Parental Leave Pay.
- Parental Leave Pay does not change other leave that your employees are allowed under an industrial agreement or the law.
- You cannot refuse paid maternity or parental leave to your employee if it is part of an industrial agreement or the law. This applies for as long as the agreement or law is in place.

For information about workplace rights and laws in English and over 30 languages go to **fairwork.gov.au** or call the Fair Work Ombudsman on **131 394**.

## For more information

- Go to **servicesaustralia.gov.au/pplemployers**
- Go to **servicesaustralia.gov.au/proda** for information about registering your business
- Go to **servicesaustralia.gov.au/yourlanguage** where you can read, listen to or watch information in your language
- Call us on **131 158 or 131 202 to speak to us in your language**.

## Disclaimer

The information contained in this publication is intended only as a guide to payments and services. It’s your responsibility to decide if you wish to apply for a payment and to make an application with regard to your particular circumstances.